ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

**ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី អន្តរាគមជួយពលករ-ពលការិនីខ្មែរចំនួន៥នាក់**

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**៥នាក់** ដូចខាងក្រោម៖

(១) ពលការិនី **ប.ផ.ន** អាយុ២៦ឆ្នាំ មកពីស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ
(២) ពលការិនី **ច.ស** អាយុ២៩ឆ្នាំ មកពីស្រុកតំបែរ ខេត្តត្បូងឃ្មុំ

ពលការិនីទាំង**២នាក់** ត្រូវបានមេខ្យល់បោកបញ្ឆោតនាំធ្វើដំណើរតាមរថយន្តកាត់តាមព្រំដែនថៃទៅម៉ាឡេស៊ី ធ្វើការងារតាមផ្ទះ កាលពីឆ្នាំ២០១៥។ ដោយការងារលំបាក និងនិយោជកមិនព្រមបើកប្រាក់ខែ ពលការិនីទាំងពីរបានទាក់ទងមកក្រុមគ្រួសារនៅកម្ពុជា ដើម្បីជួយពួកគេត្រឡប់មកកម្ពុជាវិញ។

បន្ទាប់ពីទទួលបានសំណូមពរពីក្រុមគ្រួសាររបស់ពលការិនីទាំងពីរ ស្ថានទូតបានអន្តរាគម ហើយនិយោជករបស់ពលការិនីទាំង២នាក់ បានយល់ព្រមនាំពលការិនីមកស្ថានទូត និងប្រគល់លិខិតឆ្លងដែន ប្រាក់ខែដែលនៅសល់ និងសំបុត្រយន្តហោះជូនដល់អ្នកទាំងពីរ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧។

(៣) ពលករ **ល.ឡ** អាយុ២៤ឆ្នាំ មកពីស្រុកកណ្តៀង ខេត្តពោធិ៍សាត់
(៤) ពលការិនី **ធ.យ** អាយុ៣៧ឆ្នាំ មកពីស្រុកកណ្តៀង ខេត្តពោធិ៍សាត់
(៥) ពលការិនី **ភ.ភ** អាយុ១៨ឆ្នាំ មកពីស្រុកបាកាន ខេត្តពោធិ៍សាត់

ពលករ-ពលការិនីទាំង**៣នាក់** ត្រូវបានមេខ្យល់ នាំធ្វើដំណើរតាមរថយន្តកាត់តាមព្រំដែនថៃទៅម៉ាឡេស៊ី ធ្វើការជាអ្នកលក់ដូរ កាលពីខែកក្កដា ឆ្នាំ២០១៦។ ដោយចង់ត្រឡប់មកកម្ពុជាវិញ ពួកគេបានស្នើសុំកិច្ចអន្តរាគមន៍ពីស្ថានទូត នៅថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៧ ។ ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី។

ពលករ-ពលការិនីទាំង**៥នាក់**ខាងលើ បានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី **០៥ ខែមេសា ឆ្នាំ២០១៧** វេលាម៉ោង **០៧:៣៥**នាទីព្រឹក តាមជើងយន្តហោះ AK536 ៕

ភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៧
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ